# ការប្រាស្រ័យទាក់ទងគ្នាដោយពាក្យសំដី

| វិជ្ជមាន | អវិជ្ជមាន |
|---|---|
| កំរិតល្អ នៃសំលេង | ស្រែក រឺ ខ្សិប |
| និយាយដោយសំលេងច្បាស់ៗ | និយាយរអ៊ូរៗ |
| និយាយត្រង់ៗ ហើយមានដកឃ្លាស្រមស្រប | និយាយលឿនពេក រឺ យឺតពេកៗ |
| បែរមុខរកមនុស្សដែលអ្នកកំពុងនិយាយជាមួយ | មើលក្រោម រឺ មើលទៅឆ្ងាយពីមនុស្សដែលអ្នកកំពុងនិយាយជាមួយ |
| មិនបិតមាត់ | បិតមាត់ដោយប្រើដៃ រឺ មាស់ |
| ធ្មេញស្អាត/ដង្ហើមល្អ | ធ្មេញមានជាប់សំអេក ប្រឡាក់ មានក្លិនមាត់ (សុរា ខ្ទឹម) |
| ទុកពេលអោយអ្នកដទៃឆ្លើយ | មិនទុកពេលអោយអ្នកដទៃឆ្លើយ |
| កាត់សំដីអ្នកដទៃនៅពេលសំខាន់ខ្លាំងប៉ុណ្ណោះ | កាត់សំដីអ្នកដទៃញឹកញាប់ |
| មិននិយាយបញ្ចប់ប្រយោគរបស់អ្នកដទៃ | តែងតែនិយាយបញ្ចប់ប្រយោគរបស់អ្នកដទៃ |

# ការប្រាស្រ័យទាក់ទងគ្នាដោយមិនប្រើពាក្យសំដី

| វិជ្ជមាន | អវិជ្ជមាន |
|---|---|
| និយាយមើលភ្នែកក្នុងលក្ខណៈសមគួរ (ប៉ុន្តែមិនយូរ) | មើលទៅកន្លែងដទៃ ប៉ុន្តែមិនមើលទៅមនុស្សដែលកំពុងនិយាយជាមួយ ជាពិសេសមើលនាឡិកាដៃ រឺ នាឡិកាខាងក្រោយក្បាលរបស់អ្នក |
| ខ្លួនប្រាណស្ថិតនៅក្នុងឥរិយាបថបន្ធូអារម្មណ៍ | ឥរិយាបថរឹងៗដោយបត់ដៃ រឺក៏ឥរិយាបថបន្ធូរអារម្មណ៍ជ្រុលពេក ដែលអាចអោយគេគិតរាក់ទាក់ជ្រុល រឺ គិតដល់ផ្លូវភេទ។ នៅមិនសុខ។ |
| ព្យាយាមដាក់ខ្លួនអ្នកអោយស្មើនឹងកំពស់អ្នកដែលអ្នកនិយាយទៅកាន់ | ឈរលើអ្នកដទៃ រឺ អង្គុយក្រោយតុ ហើយអោយអ្នកដទៃឈរ |
| រក្សាគំលាតសមស្រប រឺ កន្លែងរវាងអ្នក និង មនុស្សដែលអ្នកកំពុងប្រាស្រ័យទាក់ទងជាមួយ | បៀតបៀនកន្លែងឈរអ្នកដទៃ រឺ ឈរឆ្ងាយពេក |
| ទឹកមុខគួរអោយចាប់អារម្មណ៍ | ទឹកមុខគួរអោយធុញហើយស្ងាប់។ ហើយបើបានស្ងាប់ បិតមាត់ ហើយសុំទោស |
| ញញឹមម្តងម្កាល់ | មិនដែលញញឹម |
| ងូកក្បាលម្តងម្កាល់ហើយក្បាលងាកទៅម្ខាងតិចៗ | ក្បាល់ត្រង់រឹង មិនងូកក្បាល |
| មិនញ៉ាំ រឺ មិនទំពារស្ករកៅស៊ូ | ញ៉ាំ រឺ ទំពារស្ករកៅស៊ូ |
| យកចិត្តទុកដាក់ស្តាប់អ្នកដទៃទាំងស្រុង | សន្ទនាជាមួយអ្នកដទៃ។ នាំអោយមានការកាត់សំដី។ |

# ការដោះស្រាយភាពតឹងតែងក្នុងបរិយាកាសធ្វើធ្មេញ

ជារឿយៗមានជំហានមួយចំនួនដែលអាចចាត់វិធានការជួយអ្នកជំងឺដែលមានកង្វល់ច្រើននៅពេលពួកគេទៅគ្លីនិច ធ្មេញ។
ចូរកាត់បន្ថយពេលរង់ចាំសំរាប់អ្នកជំងឺប្រភេទនេះ ហើយព្យាយាមបង្កើតបរិយាកាសរាក់ទាក់ និង សប្បាយរីករាយ។
ចូរមានការបង្វែរអារម្មណ៍ដ៏គួរអោយទាក់ទាញមួយ ដូចជាមានទស្សនាវដ្តីទាន់សម័យ ក្នុងស្ថានភាពល្អ។ រក្សាពេលណាត់ជួប
ប្រសិនបើអាចទៅរួច ហើយបើមានការលើកពេល សូមពន្យល់ដល់អ្នកជំងឺ។ នែនាំខ្លួនអ្នកទៅដល់អ្នកជំងឺ
ប្រសិនបើវាជាលើកដំបូងដែលអ្នកបានជួយ ហើយហៅឈ្មោះអ្នកជំងឺអោយបានច្រើនជាងមួយដង អំឡុងពេលព្យាបាល
(ត្រូវដឹងថាគេចង់អោយអ្នកហៅគេយ៉ាងម្តេច)។ សួរអ្នកជំងឺអំពី ខ្លួនរបស់គេ (ឧទាហរណ៍ តើគេកំពុងធ្វើអ្វី អំពីកូនៗ
អំពីពេលវិស្សមកាល -ល-) ហើយព្យាយាមចៀសវាង និយាយអំពីខ្លួនរបស់អ្នកច្រើនពេក
រឺក៏និយាយទៅអ្នករួមការងារអំពីបញ្ហាផ្ទាល់ខ្លួន រឺបញ្ហាសង្គម ខណៈពេលដែល ព្រងើយកន្តើយនឹងអ្នកជំងឺ។
ចូរបង្ហាញអ្នកជំងឺថាអ្នកកំពុងស្តាប់ រឺយល់អំពីការប្រាស្រ័យទាក់ទងដោយការប្រាស័យទាក់ទងដោយពាក្យសំដី និង មិនដោយសារពាក្យ
សំដីជាលក្ខណៈវិជ្ជមាន។

ចូរអោយពេលវាលាគ្រប់គ្រាន់ដល់អ្នកជំងឺសំរាប់ឡើងលើកៅអីដោយស្រួល មុននឹងផ្អែកខ្នង មុននឹងពាក់អាវគ្រប់ការពារ
មុននឹងពាក់វែនតា និង មុននឹងបើកភ្លើង ។

ធានារ៉ាប់រងអ្នកជំងឺដោយស្មោះត្រង់ ប្រើការទាក់ទាញសមស្រប ហើយមិនប្រឌិតចំលើយ។ ប្រសិនបើមិនដឹងពីវិធី
ឆ្លើយសំនួររបស់អ្នកជំងឺ ត្រូវសួរនរណាម្នាក់ដែលដឹងចំលើយ។ សូមអោយអ្នកជំងឺដឹងពីប្រព័ន្ធដំនើរការក្នុងពេលវះកាត់ និង ក្នុងគ្លីនិច
(ការណាត់ជួប ការបង់ថវិកា ម៉ោងធ្វើការ សេវាកម្មសង្រ្គោះបន្ទាន់ -ល-) ។
សំខាន់ជាងនេះបំផុតនោះ គឺទោះជាអ្នករវល់ខ្លាំង រឺ មានអារម្មណ៍មិនល្អ មិនត្រូវបញ្ចេញវាលើអ្នកជំងឺ រឺលើមិត្តរួមការងារ
នៅពេលមានវត្តមានអ្នកជំងឺ។ ហើយក៏ត្រូវព្យាយាមញញឹម ព្រោះវាអាចអោយអ្នក និង អ្នកជំងឺមានអារម្មណ៍ប្រសើរឡើង។

**ភាពពិការភ្នែក**

ការប៉ះពាល់ទន់ភ្លន់សមស្រប ហើយ ការប្រើរលកសំលេង គឺមានសារៈសំខាន់ណាស់។
ត្រូវនិយាយទៅកាន់មនុស្សខ្សោយភ្នែក មិនមែនជាមួយអ្នកមកជាមួយអ្នកជំងឺនោះទេ។
សូមកុំចាប់ពួកគេហើយនាំពួកគេទៅធ្វើការព្យាបាលវះកាត់ សូមអោយពួកគេដាក់ដៃរបស់ពួកគេលើដៃរបស់អ្នក។
សូមអោយពួកគេប៉ះ ហើយប្រើរាល់ជំនួយការធ្វើអនាម័យមាត់ដែលបានផ្តល់អោយ។
កុំស្រែកដាក់ពួកគេ។
ជាញឹកញាប់ត្រូវប្រាប់ពួកគេមុននូវអ្វីដែលនឹងធ្វើដល់គេ។
កុំទៅឈរភ្លាមៗក្រោយអ្នកជំងឺ។

**ភាពពិការការស្តាប់**

ជាញឹកញាប់ត្រូវសំលឹងទៅអ្នកនោះ។

ត្រូវនិយាយយឺតៗ ត្រូវប្រើពាក្យដោយប្រុងប្រយ័ត្ន ហើយមិនត្រូវរអ៊ូរទេ។

មិនចាំបាច់អីត្រូវស្រែក។

អោយប៊ិច និង ក្រដាស ប្រសិនបើចាំបាច់។

ចៀសវាងសំលេងពីខាងក្រោយដែលលឺរំខានខ្លាំងពេក នៅពេលនិយាយ ព្រោះវាអោយប៉ះពាល់ដល់ប្រដាប់ជំនួយការស្ដាប់របស់គេ។

ត្រូវប៉ះថ្នមៗលើស្មា នៅពេលអ្នកចង់ទាក់ទាញការយកចិត្តទុកដាក់របស់អ្នកជំងឺប្រភេទនេះ នៅពេលដែលពួកគេងាកចេញឆ្ងាយពីអ្នក។

កុំទៅភ្លាមៗនៅក្រោមពួកគេ។

អ្នកជំងឺអាចមានត្រចៀកខាងណា អាចលឺល្អជាងម្ខាងទៀត ត្រូវចងចាំចំនុចនេះ ប្រសិនបើអ្នកជំងឺបានប្រាប់អ្នក។

**នៅពេលជួបមនុស្សពិការភ្នែក**

សូមជួយនៅពេលណាសមស្របបានហើយ។ មុននឹងធ្វើអ្វីមួយ សូមរង់ចាំជួយគេរហូតដល់ពួកគេយល់ព្រមអោយជួយ។

ត្រូវស្ដាប់នូវអ្វីដែលគេនិយាយ។

សូមប្រើតែនាមខ្លួនរបស់ជនពិការនោះបានហើយ ប្រសិនបើអ្នកក៏កំពុងហៅឈ្មោះរបស់អ្នកណាផ្សេងទៀត។

ត្រូវប្រព្រឹត្តិទៅលើជនពិការដោយក្ដីគោរព ដូចការដែលអ្នកធ្វើជាមួយអ្នកផ្សេងទៀតដែរ សូមកុំជួយនរណាម្នាក់ អោយក្រោកឈរ រឺ អង្គុយ ដោយមិនបានប្រាប់ រឺ ស្ដាប់ការឆ្លើយតបរបស់គេជាមុន។

**នៅពេលជួបមនុស្សដែលខ្សោយការមើល**

សូមនែនាំខ្លួនរបស់អ្នកនិងអ្នកដទៃអោយបានច្បាស់លាស់ ហើយត្រូវនិយាយប្រាប់ពីទីតាំងរបស់មនុស្សនៅក្នុងបន្ទប់។

ឆ្កែមគ្គុទេសគឺជាឆ្កែសំរាប់ធ្វើការងារ ហើយមិនត្រូវធ្វើដាក់វាដូចជាសត្វចិញ្ចឹមទេ។

ប្រសិនបើ អ្នកជំងឺមើលទៅដូចជាត្រូវការជំនួយ ត្រូវសួរថា តើខ្ញុំអាចជួយអ្នកបានទេ? អ្នកគួរជួយគេបានហើយ ចៀសវាងបញ្ជាគេ។

នៅពេលអ្នកចង់ចាប់ដៃ ត្រូវនិយាយថា តើយើងអាចចាប់ដៃបានទេ?

នៅពេលអ្នកអោយគេអង្គុយចុះ ត្រូវដឹកដៃអ្នកនោះទៅប៉ះដៃកៅអី រឺ កន្លែងផ្អែកនៃកៅអី ហើយនិយាយពីអ្វី ដែលអ្នកនឹងធ្វើ។

ប្រាប់គេនៅពេលអ្នកដើរចេញទៅឆ្ងាយ ដូច្នោះពួកគេមិនត្រូវគេទុកចោលអោយនិយាយម្នាក់ឯង នៅក្នុងបន្ទប់។

**នៅពេលជួបមនុស្សថ្លង់**

មានកំរិត និង ប្រភេទថ្លង់ជាច្រើនប្រភេទ ហើយមានវិធីខុសគ្នាមួយចំនួនសំរាប់មនុស្សថ្លង់ រឺមនុស្សដែលពិបាកស្ដាប់ ក្នុងការប្រាស្រ័យទាក់ទងគ្នា។

ចូរសួរមនុស្សប្រភេទនោះអោយប្រាប់អ្នកពីរបៀបដែលគេចង់ធ្វើការទំនាក់ទំនងគ្នា និង ដើម្បីជួយអ្នកអោយរកអ្នកបកប្រែ រឺរកជំនួយទុកជាមុន។

ប្រសិនបើ មានអ្នកបកប្រែភាសាកាយវិការ សូមនិយាយទៅកាន់បុគ្គលនោះ មិនមែននិយាយទៅកាន់អ្នកបកប្រែទេ។

សូមមើលទៅដោយផ្ទាល់ទៅអ្នកដែលអ្នកកំពុងនិយាយទៅជាមួយ ឈប់និយាយប្រសិនបើអ្នកត្រូវងាកមុខចេញ។

ត្រូវនិយាយអោយបានច្បាស់ៗដោយចង្វាក់សំលេងធម្មតា ហើយសុំអោយយឺតៗបន្តិច។

មិនត្រូវប្រើកាយវិការបំភ្លៃការពិតឡើយ។

ចូរអោយច្បាស់ថាអ្នកជំងឺអាចមើលឃើញអ្នកក្នុងគំហើញដ៏ល្អមួយ។

## នៅពេលជួបមនុស្សពិការភ្នែក និងថ្លង់

ថ្លង់ និង ខ្វាក់ គឺជាបន្សំរវាង ការខ្សោយការស្តាប់ និង ការខ្សោយការមើលឃើញ ប៉ុន្តែមនុស្សថ្លង់ខ្វាក់ តាមពិតទៅមិនមែនថ្លង់ រឺខ្វាក់ទាំងស្រុងទេ មនុស្សថ្លង់ខ្វាក់ភាគច្រើន ប្រាកដជាមាននៅសល់ការលឺខ្លះៗ រឺក៏សល់ការឃើញខ្លះ រឺ ក៏នៅសល់ទាំងពីរ ។ ដូច្នោះ ជំនួយទានដែលបានផ្តល់ក្នុងផ្នែក មនុស្សដែលខ្សោយការលឺ រឺ ឃើញ អាចយកមកប្រើបាន ។ លើសពីនេះទៅទៀតៈ

អោយអ្នកនោះដឹងថាអ្នកនៅទីនោះៈ ចូលទៅជិតពីខាងមុខ ហើយប៉ះដៃ រឺ ស្មាថ្នមៗ ដើម្បីទាក់ទាញអារម្មណ៍របស់ពួកគេ ។

មនុស្សថ្លង់ខ្វាក់ភាគច្រើន ត្រូវការអោយគេនាំផ្លូវ ។ មនុស្សផ្សេងៗគ្នាចូលចិត្តអោយគេនាំផ្លូវតាមរបៀបផ្សេងៗគ្នាដែរ

មនុស្សថ្លង់ខ្វាក់មួយចំនួន ធ្លាប់ទទួលរងអារម្មណ៍ស្មាក់ស្មើរ ។ កុំចាប់ រឺ រុញច្រានមនុស្សប្រភេទនេះ

សូមអោយគេដឹងថាយើងអមដំណើរគេដោយអោយពួកគេដាក់ដៃរបស់ពួកគេ លើកែងដៃរបស់យើង ។

វិធីប្រាស្រ័យទាក់ទង ដែលប្រើដោយមនុស្សថ្លង់ខ្វាក់ អាចរួមមានៈ ការអានបបូរមាត់ (lip reading) ការសរសេរកំណត់ត្រា ភាសាកាយវិការ ដែលអ្នកបកប្រែមានជំនាញពិសេសអាចប្រែសំរួល សំរាប់មនុស្សប្រភេទនេះបាន ។ Block alphabet គឺជាកន្លែងដែលអ្នកប្រើចង្អុលដៃសរសេរពាក្យលើបាតដៃរបស់មនុស្សថ្លង់ខ្វាក់នោះ ។ សរសេរលើបាតដៃទាំងមូល ហើយសរសេរអក្សរអោយច្បាស់លាស់ ។

## នៅពេលជួបមនុស្សដែលប្រើរទេះរុញ រឺ ឈើច្រត់

ប្រសិនបើអ្នកនិយាយទៅកាន់នរណាម្នាក់នៅលើកៅអីរុញ លើសពីមួយសំបក់ ត្រូវសំរួលជំហររបស់អ្នក ដូច្នេះ អ្នកស្ថិតនៅកំពស់ស្មើរគ្នា រឺក៏យ៉ាងហោចណាស់ត្រូវសួរអ្នកនោះថាតើគេចង់អោយយើងអង្គុយចុះរឺទេ ។

ប្រសិនបើតុខ្ពស់ រឺកន្លែងទទួលភ្ញៀវខ្ពស់ សូមកុំរិលទៅទល់មុខគ្នា ។

មិនត្រូវយកឈើច្រត់នរណាម្នាក់ទុកដាក់ នៅពេលគេអង្គុយឡើយ ។

ប្រសិនបើអ្នកដឹងថាវាមិនងាយស្រួលក្នុងការផ្លាស់ប្តូរទីតាំងជុំវិញអាគាររបស់អ្នកដោយប្រើកៅអីរុញទេនោះ ត្រូវជួយពួកគេ ទ្វារធ្ងន់ៗរឺ ព្រំក្រាស់ៗ គឺជាគ្រោះថ្នាក់មួយចំនួនដែលត្រូវអង្កេតមើល ។

សូមកុំស្មានថាជំរាលផ្លូវអាចជួយអ្វីៗគ្រប់យ៉ាង ជំរាលអស់នោះអាចចោតខ្លាំងរឺចុះទាបខ្លាំង រឺក៏រអិល ។

## នៅពេលជួបមនុស្សមានការលំបាកក្នុងការនិយាយស្តី

ចូរផ្តោតការយកចិត្តទុកដាក់លើមនុស្សដែលពិបាកនិយាយស្តី ចូរមានការអត់ធ្មត់ និង លើកទឹកចិត្តមិនអោយ ព្យាយាមបញ្ចប់ប្រយោគរបស់ពួកគេឡើយ ។

ពាក្យសំដីយឺតៗ រឺខ្សោយ មិនទាក់ទងនឹងភាពវៃឆ្លាត់របស់នរណាម្នាក់ឡើយ ។

ប្រសិនបើអ្នកត្រូវការពត៌មាន ត្រូវចេះសួរដើម្បីអាចដោះស្រាយជាមួយគោលបំណងបុគ្គលម្នាក់ៗបាន ។

សូមកុំធ្វើពុតជាយល់ ប្រសិនបើអ្នកមិនយល់ទេនោះ ។

## អ្នកជំងឺដែលមានទ្រង់ទ្រាយមុខខុសប្រក្រតី

ប្រសិនបើអ្នកភ្ញាក់ផ្អើលដោយសាររូបរាង រឺមានអារម្មណ៍មិនស្រួល ព្យាយាមមិនបង្ហាញអាការៈទាំងអស់នោះ ។

និយាយដោយសំលឹងភ្នែកគ្នា ដូចកាលដែលអ្នកនៅជាមួយអ្នកដទៃ តែមិនត្រូវសំឡក់ទេ ។

ចូរត្រង់ត្រាប់ស្តាប់ដោយយកចិត្តទុកដាក់ ហើយកុំអោយរូបរាងខាងក្រៅរបស់អ្នកនោះ រំខានអ្នកបាន ។

សូមកុំសួរថា មានអ្វីកើតឡើងចំពោះអ្នក? ត្រូវចេះគ្រប់គ្រង ការចង់ដឹងចង់លឺរបស់អ្នក ។